# អង្គការ សកម្មភាពសម្រាប់ការអប់រំនៅកម្ពុជា

**Kampuchea Action to Promote Education (KAPE)**

## សេចក្តីជូនដំណឹងស្តីពី

## ការអញ្ជើញចូលរួមដេញថ្លៃការបំពាក់គ្រឿងសង្ហារិមបណ្ណាល័យ នៅក្នុងសាលារៀនគោលដៅ របស់គម្រោង "ការអប់រំដើម្បីបង្កើនលទ្ធភាពការងារដល់យុវជននៅកម្ពុជា" ក្រោមជំនួយថវិកាដោយ អង្គការ ឆាលហ្វាន ប្រទេសអាល្លឺម៉ង់

អង្គការ សកម្មភាពសម្រាប់ការអប់រំនៅកម្ពុជា (អង្គការ ខេប) សូមជម្រាបជូនដំណឹងដល់ក្រុមហ៊ុន និងសហគ្រាស/សិប្បកម្ម ក្នុងស្រុកទាំងអស់ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាឱ្យបានជ្រាបថា៖ គម្រោង "ការអប់រំដើម្បីបង្កើនលទ្ធភាពការងារដល់យុវជននៅកម្ពុជា" នៃអង្គការ សកម្មភាពសម្រាប់ការអប់រំនៅកម្ពុជា នឹងដាក់ឱ្យដេញថ្លៃជាសាធារណៈដើម្បីជ្រើសរើសក្រុមហ៊ុន និងសហគ្រាស/សិប្បកម្ម **ទទួលការងារបំពាក់គ្រឿងសង្ហារិមបណ្ណាល័យនៅក្នុងសាលារៀនគោលដៅចំនួន ១០ ដែលមាន ១០បន្ទប់ ក្នុងខេត្ត កំពង់ចាម ចំនួន៖ ០៤បន្ទប់, ខេត្ត ត្បូងឃ្មុំ ចំនួន៖ ០៣បន្ទប់ និងខេត្ត កំពង់ឆ្នាំង មាន៖ ០៣បន្ទប់។**

ក្រុមហ៊ុន និងសហគ្រាស/សិប្បកម្ម ទាំងអស់ដែលមានប្រភពតែមួយអាចដាក់សំណើដេញថ្លៃបានតែមួយគត់ ក្នុងករណីពិនិត្យឃើញថា៖ ក្រុមហ៊ុន និងសហគ្រាស/សិប្បកម្ម ដែលបានចូលរួមធ្វើការដេញថ្លៃ ជាក្រុមហ៊ុន និងសហគ្រាស/សិប្បកម្ម មានសម្ព័ន្ធភាពជាមួយ ឬប្រភពតែមួយ នឹងត្រូវបដិសេធដោយស្វ័យប្រវត្តិ។

**ក្រុមហ៊ុន និងសហគ្រាស/សិប្បកម្ម ដែលមានចំណាប់អារម្មណ៍សូមធ្វើការទាក់ទងមកអង្គការ សកម្មភាពសម្រាប់ការអប់រំនៅកម្ពុជា ដើម្បីសាកសួរព័ត៌មានអំពីការចូលរួមដេញថ្លៃ និងការរៀបចំឯកសារភ្ជាប់ក្នុងការបញ្ជាក់លក្ខណៈសម្បត្តិរបស់អ្នកចូលរួមដេញថ្លៃ ចាប់ពីថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២៦ ដល់ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២៦ ម៉ោង៥:០០នាទីល្ងាចជាកំហិត តាមរយៈសារអេឡិចត្រូនិច (អ៊ីមែលជូនភ្ជាប់) ព្រមទាំងចម្លងជូន (CC) មកអ្នកពាក់ព័ន្ធទាំងអស់។**

**អង្គការ សកម្មភាពសម្រាប់ការអប់រំនៅកម្ពុជា (អង្គការ ខេប) នឹងធ្វើការប្រជុំតម្រង់ទិសអំពីនិតិវិធីនៃការបំពេញសម្រង់តម្លៃសម្រាប់ចូលរួមដេញថ្លៃតាមរយៈអនឡាញ ដែលប្រព្រឹត្តិទៅនៅ ថ្ងៃទី០២ ខែមីនា ឆ្នាំ២០២៦ វេលាម៉ោង ០៩:៣០នាទីព្រឹក ចំពោះតំណរភ្ជាប់សម្រាប់ធ្វើអនឡាញ យើងខ្ញុំនឹងផ្ញើតាមអ៊ីមែល ឬតេឡេក្រាម។**

ក្រោយពីការប្រជុំតម្រង់ទិសរួច ក្រុមហ៊ុននិងសហគ្រាស/សិប្បកម្ម ទាំងអស់ត្រូវរៀបចំឯកសារសម្រង់តម្លៃនៃការបំពាក់គ្រឿងសង្ហារិមបណ្ណាល័យចំនួន៖ ១០បន្ទប់នោះជាប្រាក់រៀលដោយមានការបញ្ចូលពន្ធអាករលើតម្លៃបន្ថែម ១០%ផងដែរ។

**ចំពោះការបើកកញ្ចប់ឯកសារដេញថ្លៃនឹងប្រព្រឹត្តិទៅដោយផ្ទាល់នៅថ្ងៃទី០៥ ខែមីនា ឆ្នាំ២០២៦ ដែលមានអាសយដ្ឋាននៅការិយាល័យកណ្តាល ភូមិទី៦, សង្កាត់ វាលវង់, ក្រុង កំពង់ចាម, ខេត្ត កំពង់ចាម (ស្ថិតនៅក្នុងបរិវេណសាលាគរុកោសល្យ និងវិក្រឹតការ ខេត្ត កំពង់ចាម)។**

**<u>បញ្ជាក់៖</u>**

- ការទទួលឯកសារភ្ជាប់បញ្ជាក់លក្ខណៈសម្បត្តិរបស់អ្នកចូលរួមដេញថ្លៃចាប់ពីថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២៦ ដល់ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២៦ វេលាម៉ោង ៥:០០នាទីល្ងាចជាកំហិត តាមរយៈសារអេឡិចត្រូនិច (អ៊ីម៉ែលជូនភ្ជាប់) ព្រមទាំងចម្លងជូន (CC) មកអ្នកពាក់ព័ន្ធទាំងអស់។
- ការប្រជុំតម្រង់ទិសអំពីនិតិវិធីនៃការបំពេញសម្រង់តម្លៃសម្រាប់ចូលរួមដេញថ្លៃតាមរយៈអនឡាញប្រព្រឹត្តិទៅថ្ងៃទី០២ខែមីនា ឆ្នាំ២០២៦ វេលាម៉ោង ០៩:៣០នាទីព្រឹក (តំណរភ្ជាប់សម្រាប់ធ្វើអនឡាញ យើងខ្ញុំនឹងផ្ញើតាមអ៊ីមែល ឬតេឡេក្រាម)។
- រាល់ឯកសារសម្រង់តម្លៃ (ត្រូវបញ្ចូលពន្ធអាករលើតម្លៃបន្ថែម ១០%) ដោយគិតជាប្រាក់រៀល និងពាក្យសុំចូលរួមការដេញថ្លៃទាំងអស់ត្រូវប្រេកក្នុងស្រោមបិទជិត ដោយមានចុះហត្ថលេខា និងបោះត្រារបស់ក្រុមហ៊ុន និងសហគ្រាស/សិប្បកម្ម នៅលើស្រោមសំបុត្ររួចបញ្ជូនមកការិយាល័យរដ្ឋបាល នៃអង្គការ សកម្មភាពសម្រាប់ការអប់រំនៅកម្ពុជា (អង្គការ ខេប) ចាប់ពីថ្ងៃទី ០៣ ខែមីនា ឆ្នាំ២០២៦ ដល់ថ្ងៃទី០៤ ខែមីនា ឆ្នាំ២០២៦ វេលាម៉ោង ៥:០០នាទីល្ងាច ជាកំហិត ដែលមានអសយដ្ឋាននៅ

ការិយាល័យកណ្តាល ភូមិទី៦, សង្កាត់ វាលវង់, ក្រុង កំពង់ចាម, ខេត្ត កំពង់ចាម (ស្ថិតនៅក្នុងបរិវេណសាលាគរុកោសល្យ និងវិក្រឹតការ ខេត្ត កំពង់ចាម) ហើយមិនអនុញ្ញាតឱ្យដាក់មកតាមរយៈសារអេឡិចត្រូនិច (អ៊ីមែល) បានជាដាច់ខាត។

- រាល់ឯកសារសម្រង់តម្លៃ និងពាក្យសុំចូលរួមការដេញថ្លៃទាំងអស់ ដែលមិនបានដាក់ជូនមកការិយាល័យរដ្ឋបាលរបស់អង្គការសកម្មភាពសម្រាប់ការអប់រំនៅកម្ពុជា ទាន់ពេលវេលាទេ ត្រូវចាត់ទុកជាអាសាបង់។
- អ្នកចូលរួមដេញថ្លៃទាំងអស់ ត្រូវអញ្ជើញមកចូលរួមប្រជុំស្តាប់ការបើកកញ្ចប់ដេញថ្លៃឱ្យទាន់ពេលវេលា។ ប្រសិនបើអ្នកដេញថ្លៃណាដែលមិនបានចូលរួមប្រជុំបើកកញ្ចប់ដេញថ្លៃទាន់ពេលវេលា ឬក៏អវត្តមានក្នុង(រយៈពេល១៥នាទី)ឯកសារដាក់ដេញថ្លៃនោះមិនអនុញ្ញាតដាក់បញ្ចូលក្នុងការបើកឡើយ។
- ចំពោះអ្នកចូលរួមប្រជុំការបើកកញ្ចប់ឯកសារដេញថ្លៃទាំងអស់ដែលជាអ្នកមកតំណាងក្រុមហ៊ុននិងសហគ្រាស/សិប្បកម្ម ត្រូវមានលិខិតផ្ទេរសិទ្ធិ ដែលមានចុះហត្ថលេខាត្រឹមត្រូវពីប្រធានក្រុមហ៊ុន និងសហគ្រាស/សិប្បកម្ម។
- យើងខ្ញុំសូមរក្សាសិទ្ធិក្នុងការផ្លាស់ប្តូរកាលបរិច្ឆេទនៃការបើកកញ្ចប់ដេញថ្លៃ ប្រសិនបើមានការចាំបាច់ ហើយយើងខ្ញុំនឹងជូនដំណឹងជាមុនទៅក្រុមហ៊ុន និងសហគ្រាស/សិប្បកម្ម ដែលបានផ្ញើឯកសារដេញថ្លៃមក។
- រាល់ឯកសារដែលដាក់មកហើយ គណៈកម្មការយើងខ្ញុំមិនប្រគល់ជូនត្រឡប់ទៅវិញទេ។

**ព័ត៌មានផ្សេងៗសូមទំនាក់ទំនង៖**

ការិយាល័យកណ្ដាលអង្គការ សកម្មភាពសម្រាប់ការអប់រំនៅកម្ពុជា (អង្គការ ខេប )

| | | | |
|---|---|---|---|
| អាសយដ្ឋាន | ៖ | ក្នុងបរិវេណសាលាគរុកោសល្យ និងវិក្រឹតការ ខេត្ត កំពង់ចាម | |
| ឈ្មោះ | ៖ | លោក ឈួន សារ៉ាន | ប្រធានរដ្ឋបាល និងធនធានមនុស្ស |
| | ៖ | លោក ទុំ ទីតូណា | ប្រធានគម្រោង |
| | ៖ | លោក ម៉ៃ សារិទ្ធិ | ប្រធានសម្របសម្រួលគម្រោង |
| ទូរសព្ទ | ៖ | ០១២ ៧៥២ ៥៥៣, ០៩៦ ៤៦៤ ៧៧៧៧ | |
| អ៊ីមែល (To) | ៖ | saran@kapekh.org | |
| ចម្លងជូន (CC) | ៖ | vanna@kapekh.org, sambath@kapekh.org, titona@kapekh.org, sarith@kapekh.org, than.sreyvy@kapekh.org, veasna@kapekh.org | |

ថ្ងៃចន្ទ ៧កើត ខែផល្គុន ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
កំពង់ចាម, ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២៦
**នាយកប្រតិបត្តិ**

**សៅ.វណ្ណា**